# សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលស្តីពីសេចក្តីសន្និដ្ឋាននៃការសង្កេតមើលរបស់គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកលើអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍ ទាក់ទងទៅនឹងបញ្ហានានារបស់ជនជាតិដើមភាគតិច

អង្គការមិនមែនរដ្ឋាភិបាលនានា ដែលធ្វើការទៅលើសិទ្ធិមនុស្ស និងសិទ្ធិជនជាតិដើមភាគតិច បានធ្វើការពិនិត្យឡើងវិញនូវសេចក្តីសន្និដ្ឋាននៃការសង្កេតមើលរបស់គណៈកម្មាធិការអង្គការសហប្រជាជតិទទួលបន្ទុកលើអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍ ។

ចំនុចសំខាន់ៗដែលទាក់ទងទៅនឹងសិទ្ធិជនជាតិដើមភាគតិចទាំងឡាយមានដូចតទៅ:

- គណៈប្រតិភូរាជរដ្ឋាភិបាលដែលបានចូលរួមពិភាក្សាអនុសញ្ញាអន្តរជាតិស្តីអំពីការលុបបំបាត់ការរើសអើងពូជសាសន៍ (ICERD) នៅទីក្រុងហ្សឺណែវកាលពីខែ កុម្ភៈ កន្លងទៅនេះ មិនមានសមាសភាពតំណាងពីក្រសួងពាក់ព័ន្ធ ឬអង្គភាពនានានៅក្នុងប្រទេសកម្ពុជានោះទេ ។
- គណៈកម្មាធិការបានធ្វើការកត់សំគាល់យ៉ាងយកចិត្តទុកដាក់ទៅលើការអនុមតិច្បាប់ភូមិបាលឆ្នាំ ២០០១ ព្រមទាំងទៅលើអនុក្រិត្យមួយចំនួនជាបន្តបន្ទាប់ផងដែរ ។
- គណៈកម្មាធិការបានសំដែងការព្រួយបារម្ភណ៍ទៅលើរបាយការណ៍អន្តរាគមន៍ផ្នែកនយោបាយនានា និងអំពើពុករលួយដែលប៉ះពាល់ទៅលើស្ថាប័នតុលាការទាំងឡាយ ព្រមទាំងប៉ះពាល់ទៅលើដំណើរការប្រព្រឹត្តទៅនៃការផ្តល់នូវសេវាសាធារណៈមួយចំនួនផងដែរ ។
- ប្រទេសកម្ពុជាគួរតែបន្ត និងបង្កើនការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីពង្រឹង និងធានានូវឯករាជភាពនៃស្ថាប័នតុលាការ ។
- ប្រទេសកម្ពុជាគួរតែចាត់វិធានការណ៍ទាំងឡាយដើម្បីធ្វើការពង្រឹងនូវសមត្ថភាពរបស់ខ្លួនក្នុងការស៊ើបអង្កេត និងដាក់ពិន័យក្នុងករណីអសមត្ថភាព និងអំពើពុករលួយដែលកើតមានឡើងនៅក្នុងស្ថាប័នរបស់ខ្លួន ។
- ក្នុងករណីខ្លះ ដំណើរស្វែងរកឱ្យមានការរីកចំរើនសេដ្ឋកិច្ច និងភាពសំបូររុងរឿងត្រូវបានគេបន្តធ្វើឡើង ដែលបានធ្វើឱ្យមានការខូចប្រយោជន៍ជាពិសេសដល់សហគមន៍ដែលងាយនឹងទទួលរងគ្រោះទាំងឡាយ រួមមាន ជនជាតិដើមភាគតិចជាដើម ។
- គណៈកម្មាធិការបានសំដែងការព្រួយបារម្ភណ៍ជាពិសេសទៅលើរបាយការណ៍នៃការផ្តល់សម្បទានយ៉ាងឆាប់រហ័សនៅលើដីធ្លីដែលជនជាតិដើមភាគតិចបានកាន់កាប់ជាប្រពៃណីរួចមកហើយ ដោយមិនបានធ្វើការពិចារណាឱ្យបានសព្វជ្រុងជ្រោយ ឬការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវនីតិវិធីដូចដែលមានចែងនៅក្នុងច្បាប់ភូមិបាល និងអនុក្រិត្យដែលមានការពាក់ព័ន្ធ។
- ប្រទេសកម្ពុជាគួរតែធានាថាឱ្យមានការសំរេចបាននូវតុល្យាភាពដ៏សមស្របរវាងការអភិវឌ្ឍន៍ និងសិទ្ធិពលរដ្ឋរបស់ខ្លួន ហើយនឹងធ្វើការធានាផងដែរថា ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួននឹងមិននាំមកនូវការលះបង់សិទ្ធិរបស់បុគ្គលនានា និងក្រុមដែលងាយទទួលរងគ្រោះទាំងឡាយនោះទេ ។
- ប្រទេសកម្ពុជាគួរតែបង្កើតនូវវិធានការដ៏សមស្របដើម្បីការពារដីធ្លីជនជាតិដើមភាគតិច ដោយរួមទាំងការពន្យានូវសម្បទានទាំងឡាយ និងការស្វែងរកនូវការយល់ព្រមដោយសេរី និងបានជំរាបជាមុនពីសហគមន៍ជនជាតិដើមភាគតិចមុននឹងធ្វើការផ្តល់សម្បទាននានា។

- ក្រុមហ៊ុនសាជីវកម្មទាំងឡាយគួរតែយកចិត្តទុកដាក់នូវទំនួលខុសត្រូវផ្នែកសង្គមរបស់សាជីវកម្មខ្លួន ដោយហេតុថាវាមានទំនាក់ទំនងទៅនឹងសិទ្ធិ និងសុខមាលភាពរបស់ប្រជាជននៅក្នុងតំបន់ ។
- គណៈកម្មាធិការបានសំដែងការព្រួយបារម្ភចំពោះរបាយការណ៍ស្តីពីការបំភិតបំភ័យ និងអំពើរំលោភបំពាន់ទៅលើជនជាតិភាគតិចក្នុងកំឡុងពេលធ្វើការជន្លៀសចេញដោយបង្ខំ ឬក្នុងពេលមានជម្លោះដីធ្លី ដែលបានធ្វើឱ្យប៉ះពាល់ដល់ពួកគេ ។
- ប្រទេសកម្ពុជាគួរតែផ្តល់ការការពារឱ្យបានពេញលេញទៅដល់ក្រុមដែលងាយទទួលរងគ្រោះទាំងឡាយ អំពីសំណាក់ការវាយប្រហារទៅលើរូបរាងកាយ និងការបំភិតបំភ័យ ក្នុងខណៈដែលពួកគេស្វែងរកការអនុវត្តនូវសិទ្ធិរបស់ខ្លួន ដោយហេតុតែសិទ្ធិទាំងនោះមានការទាក់ទងទៅនឹងដីធ្លីរបស់សហគមន៍ និងគួរតែចាប់បញ្ជូនអ្នកប្រព្រឹត្តបទល្មើសនៃរំលោភបំពានទាំងនោះទៅកាត់ទោសនៅមុខតុលាការ ។
- គណៈកម្មាធិការបានសំដែងការព្រួយបារម្ភអំពីភាពមិនស្របគ្នាដោយអន្លើនូវសិទ្ធិទទួលបានការសិក្សា ជាពិសេសតំបន់ជនបទដាច់ស្រយាលនានា ។ ហើយដោយឡែក គណៈកម្មាធិការមានការព្រួយបារម្ភអំពីការសិក្សារបស់កុមារនៅក្នុងខេត្តមណ្ឌលគីរី និងរតនគីរីជាដើម ។
- ប្រទេសកម្ពុជាគួរតែបន្តការខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីសំរេចបាននូវគោលដៅរបស់ខ្លួនគឺ "ការសិក្សាសំរាប់ទាំងអស់គ្នា " ហើយនឹងគួរតែពិចារណាឱ្យមានកម្មវិធីសិក្សាដែលមានពីរភាសានៅក្នុងតំបន់ជនបទដាច់ស្រយាលនានាប្រសិនបើអាចធ្វើបាន ។

អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ ដែលបានធ្វើការជាមួយជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា បានសំដែងការគាំទ្រនូវសេចក្តីសំរេចរបស់គណៈកម្មាធិការអង្គការសហប្រជាជាតិ ហើយទាំងការធ្វើសេចក្តីអង្កេត និងទាំងការធ្វើអនុសាសន៍ គឺមានភាពត្រឹមត្រូវទាំងស្រុង ហើយគណៈកម្មាធិការក៏គួរតែដាក់បន្ថែមទៀតថា ស្ថានភាពនេះគឺមានភាពប្រញាប់ប្រញាល់ និងខ្លាំងក្លាបំផុត ។ ប្រសិនបើគេមិនបានធ្វើអ្វីមួយជាបន្ទាន់ដើម្បីកែប្រែបញ្ហាទាំងអស់នោះទេ ក្រុមជនជាតិដើមភាគតិចនានា និងវប្បធម៌ទាំងមូលរបស់ពួកគេ ទំនងជាត្រូវបាត់បង់ទាំងស្រុង ។

" យើងចង់អោយរដ្ឋាភិបាលផ្តោតលើការយកចិត្តទុកដាក់ក្នុងការអនុវត្តន៍ច្បាប់ដែលមានស្រាប់ទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដើម្បីលើកកំពស់សិទ្ធជនជាតិដើមភាគតិចឱ្យមានប្រសិទ្ធភាព" (លោក ឈិត សំអាត នាយកប្រតិបត្តិវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា)

" ជនជាតិដើមភាគតិចនៅប្រទេសកម្ពុជាកំពុងតែមានវិបត្តិ ហើយពួកគេបាននិយាយទៅកាន់អង្គការសហប្រជាជាតិ និងជាការល្អដែលអង្គការសហប្រជាជាតិបានទទួលស្គាល់នូវបញ្ហានេះ" (លោក ម៉ម វុទ្ធី ប្រធានកម្មវិធីមជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍)

"សិទ្ធិជនជាតិដើមភាគតិចចំពោះទឹកដីរបស់ពួកគេត្រូវបានគេរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ហើយបញ្ហានេះមានសភាពធ្ងន់ធ្ងរបំផុតដូច្នេះគ្រប់បណ្តាភាគីដែលមានការពាក់ព័ន្ធ មិនអាចធ្វើការព្រងើយកន្តើយ នូវអ្វីៗដែលកំពុងតែ កើតមានឡើងនោះបានទេ" (លោក សួន សារ៉េត លេខាប្រតិបត្តិ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា)

" សិទ្ធិរបស់ប្រជាជនកម្ពុជាទាំងអស់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសិទ្ធិរបស់ជនជាតិដើមភាគតិច ។ ជនជាតិដើមភាគតិចការពារធនធានធម្មជាតិដែលទទួលខុសត្រូវនូវស្ថេរភាពផ្នែកបរិស្ថាននៃតំបន់ទំនាបកណ្តាលនៃប្រទេសកម្ពុជា ។

ប្រសិនបើយើងអនុញ្ញាតិឱ្យមានការរំលោភបំពានចេះតែបន្តទៅទៀតទៅលើជនជាតិដើមភាគតិច វានឹងមានការប៉ះពាល់ដល់ពួកយើងទាំងអស់គ្នាជាមិនខានឡើយ" (លោក សៀវ ភារម្យ អគ្គលេខាធិការក្រុមការងារសិទ្ធិលំនៅស្ថាន)

"ម្ចាស់ជំនួយនានា និងផ្នែកអាជីវកម្មផ្សេងៗដែលមានបំណងធ្វើវិនិយោគសំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងអន្តរជាតិគួរតែធ្វើការពិចារណាឡើងវិញថាតើការឱ្យវិនិយោគទុនរបស់ពួកគេមានសមធម៌ និងសមភាពសេដ្ឋកិច្ចរបៀបណា ហើយគួរពិនិត្យលើការវិនិយោគទុនរបស់ខ្លួនដែលមានការរំលោភលើសិទ្ធជនជាតិដើមភាគតិចឡើងវិញ (លោក សៅ វណ្ណសី នាយកប្រតិបត្តិនៃអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច) ។

"នៅពេលដែលបញ្ហារបស់ជនជាតិដើមភាគតិចត្រូវបានលើកឡើងនៅក្នុងរបាយការណ៍ CERD ដែលប៉ះពាល់ដល់ជនជាតិដើមភាគតិច ក៏ជាពេលដែលមានការរំលោភបំពានលើសិទ្ធដីធ្លី និងសិទ្ធព្រៃឈើនៅទូទាំងប្រទេស។ ជនជាតិខ្មែរក៏ជាក្រុមដែលរងផលប៉ះពាល់ពីការរំលោភបំពាននោះដែរ" (លោក ឈិត សំអាត នាយកប្រតិបត្តិវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា)

សេចក្តីថ្លែងការណ៍នេះធ្វើការផ្សព្វផ្សាយដោយវេទិកាអង្គការក្រៅរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងក្រុមការងារសិទ្ធិលំនៅស្ថាន។

ភ្នំពេញ, ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១០

**ចំពោះពត៌មានបន្ថែមសូមទាក់ទង:**

លោក **ឈិត សំអាត**
នាយកប្រតិបត្តិ
វេទិកាអង្គការមានមែនរដ្ឋាភិបាលស្តីពីកម្ពុជា
សារអេឡិចត្រូនិច :samath@ngoforum.org.kh
ទូរស័ព្ទលេខ: ០១២ ៩២៨ ៩៨៥ (សំរាប់ការហៅពីបរទេសសូមវាយលេខ ៨៥៥១២១២៩២៨៩៨៥)

លោក **សួន សារ៉េត**
លេខាប្រតិបត្តិ
គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
សារអេឡិចត្រូនិច: chrac@everyday.com.kh
ទូរស័ព្ទលេខ: (៨៥៥)៩២ ៣៨៤ ៣៥៧

លោក **សៀវ ភារម្យ**
អគ្គលេខាធិការ
ក្រុមការងារសិទ្ធិលំនៅស្ថាន
សារអេឡិចត្រូនិច :phearumsia@yahoo.com
ទូរស័ព្ទលេខ : (៨៥៥)១២ ៨៥២ ៣២៥